**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ: ០១ សរណន**

# សារាចរណែនាំ

## ស្តីពី

## ការប្រើប្រាស់កម្រងកម្មវិធីពុម្ពអក្សរខ្មែរយូនីកូដ ( Khmer Unicode )

កន្លងមក អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា(NiDA) បានបង្កើតនូវកម្រងកម្មវិធីពុម្ពអក្សរខ្មែរយូនីកូដមួយ ដែលមានលក្ខណៈងាយស្រួលក្នុងការប្រើប្រាស់ ។

ទីស្តីការគណៈរដ្ឋមន្ត្រី សូមធ្វើការណែនាំដល់គ្រប់ស្ថាប័ន អង្គភាព និងអាជ្ញាធរក្រោមឱវាទទីស្តីការគណៈរដ្ឋមន្ត្រីទាំងអស់ ត្រូវប្រើពុម្ពអក្សរខ្មែរយូនីកូដ ក្នុងការផលិត និងរៀបចំគ្រប់ឯកសាររដ្ឋបាល ឬលិខិតបទដ្ឋានគតិយុត្តនានា សំដៅឱ្យមានការឯកភាពគ្នា និងជួយសម្រួលការងារនៅក្នុងក្របខ័ណ្ឌទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីទាំងមូល ។ ចំពោះកម្រងកម្មវិធីគំរូអក្សរខ្មែរយូនីកូដ និងរបៀបប្រើប្រាស់ សូមទំនាក់ទំនងជាមួយអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (NiDA) ។

ទទួលបានសារាចរណែនាំនេះ ស្ថាប័ន អង្គភាព និងអាជ្ញាធរនានាក្រោមឱវាទ ទីស្តីការគណៈរដ្ឋមន្ត្រីត្រូវចាត់ចែងអនុវត្តជាកំហិតក្នុងស្មារតីទទួលសខុសត្រូវខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី 21 ខែ សីហា ឆ្នាំ 2009

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

-គ្រប់ស្ថាប័ន អង្គភាព និងអាជ្ញាធរចំណុះទីស្តីការគណៈរដ្ឋមន្ត្រី

-ឯកសារ-កាលប្បវត្តិ